**សុន្ទរកថាឯកឧត្តម ហូរីណូអ៊ុជិ ហ៊ីដេហ៊ីសា ឯកអគ្គរាជទូតជប៉ុនប្រចាំកម្ពុជា**
**ថ្លែងក្នុងពិធីបើកមហោស្រពគីហ្សូណា ជប៉ុន-កម្ពុជា ឆ្នាំ២០១៧**

*ថ្ងៃព្រហស្បតិ៍ ទី២៣ ខែកុម្ភៈ*

សូមគោរព!

ឯកឧត្តម **ហង់ ជួនណារុន** រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

ឯកឧត្តម **ហ៊ឹង ថូរ៉ាក់ស៊ី** រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី តំណាងដ៏ខ្ពង់ខ្ពស់ឯកឧត្តមបណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

សូមគោរព សម្តេច ឯកឧត្តម លោកជំទាវ លោក លោកស្រី ភ្ញៀវកិត្តិយសជាទីមេត្រី

ខ្ញុំសូម ស្វាគមន៍យ៉ាងកក់ក្តៅ ចំពោះភ្ញៀវកិត្តិយសទាំងអស់ ដែលបានអញ្ជើញចូលរួម **មហោស្រពគីហ្សូណា ជប៉ុន-កម្ពុជា ឆ្នាំ២០១៧** នាពេលរាត្រីនេះ។

ពាក្យ "គីហ្សូណា" មានន័យថា ចំណងជាមួយអ្នកសំខាន់ៗដូចជា គ្រួសារ ឬ មិត្តិភក្តិ ជាដើម។ យើងបានជ្រើសរើស ប្រធានបទសម្រាប់មហោស្រពគីហ្សូណាឆ្នាំ២០១៧នេះគឺ **"ធ្វើដំណើរទៅកាន់ប្រទេសជប៉ុន"** ត្រូវបានជ្រើសរើស ដើម្បីអបអរការចាប់ផ្តើមជើងហោះហើរត្រង់រវាងជប៉ុន-កម្ពុជា កាលពីខែកញ្ញា ឆ្នាំ២០១៦ កន្លងទៅ។

រយៈពេល៤ថ្ងៃនៃមហោស្រពនេះ មានកម្មវិធីវប្បធម៌ជាច្រើនបន្តបន្ទាប់។ ក្នុងនោះមានមូលនិធិជប៉ុនបានអញ្ជើញក្រុមសម្តែងក្បាច់រាំទំនើប TEMPURA KIDZ ។ ពួកគេនឹងសម្តែងក្បាច់រាំផ្ទាល់ខ្លួន និងសម្តែងរួមគ្នាជាមួយក្រុមរបាំប្រពៃណីកម្ពុជា និង តារាចម្រៀងយុវវ័យកម្ពុជានារាត្រីនេះផងដែរ។

ទន្ទឹមនឹងនេះ នឹងមានកម្មវិធីដូចជា ការប្រគំតន្ត្រី ការបង្ហាញម៉ូដនៃសម្លៀកបំពាក់ប្រពៃណីជប៉ុន ការបង្ហាញកីឡាយុទ្ធសិល្ប៍ជប៉ុន និងកម្ពុជា ជាដើម។

ក្រៅពីកម្មវិធីវប្បធម៌ទាំងនេះ យើងខ្ញុំបានរៀបចំកម្មវិធីពិពរណ៌ទេសចរណ៍ នៅច្រកចូលកន្លែងទទួលភ្ញៀវCJCC(Lobby) ដើម្បីជាការឆ្លើយតបទៅនឹងការកើនឡើងនៃចំណាប់អារម្មណ៍របស់កម្ពុជាចំពោះជប៉ុន។

ខ្ញុំសូមគោរពអញ្ជើញភ្ញៀវកិត្តិយសទាំងអស់ ចូលរួមក្នុងកម្មវិធីពិសេសៗទាំងនោះ។ កម្មវិធីទាំងនោះ ជាឱកាសដ៏ល្អមួយ បង្ហាញពីភាពសំបូរបែបនៃវប្បធម៌ និង សិល្បៈជប៉ុន។

ជាចុងក្រោយ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងអស់ពីដួងចិត្ត ចំពោះបុគ្គលិក អ្នកស្ម័គ្រចិត្តទាំងអស់នៃ CJCC និង មជ្ឈមណ្ឌលមូលនិធិជប៉ុននៅអាស៊ី ដែលសហការរៀបចំមហោស្រពនេះ និងសិល្បករសម្តែងថ្ងៃនេះ ព្រមទាំង អ្នកឧបត្ថម្ភ និងអ្នកគាំទ្រទាំងអស់ ក្នុងការចូលរួមសហការ ដើម្បីឲ្យមហោស្រពនេះប្រព្រឹត្តិទៅបាន។

សូមចូលរួមជាមួយមហោស្រពនេះដោយរីករាយ!